# ការសម្រេចបានវឌ្ឍនភាព៖ ការវិនិយោគផ្នែកហេដ្ឋារចនាសម្ព័ន្ធរបស់ចិនក្នុងតំបន់អាស៊ាន និងលើសពីនេះ

inclusive development international

## ព្រឹត្តិប័ត្រព័ត៌មានទី១៖ សង្ខេប

ក្នុងអំឡុងទសវត្សរ៍កន្លងទៅ ប្រទេសចិនបានក្លាយជាអ្នកដើរតួនាទីដ៏សំខាន់មួយនៅក្នុងការវិនិយោគ និងការផ្តល់ហិរញ្ញវត្ថុកម្រិតពិភពលោក។ ការងារនេះអាចធ្វើទៅបាន អាស្រ័យដោយមានការគាំទ្រយ៉ាងខ្លាំងពីរដ្ឋាភិបាលចិន និងការផ្គត់ផ្គង់ហិរញ្ញប្បទានពីធនាគារគោលនយោបាយ និងធនាគារពាណិជ្ជកម្មរបស់ចិន។ តួនាទីរបស់ប្រទេសចិននៅក្នុងវិស័យហិរញ្ញវត្ថុសាកលលោក ត្រូវបានជម្រុញឱ្យរីកដុះដាលកាន់តែខ្លាំងថែមទៀត តាមរយៈការអភិវឌ្ឍធំៗនាពេលថ្មីៗនេះ ដោយក្នុងនោះការអភិវឌ្ឍដ៏លេចធ្លោបំផុតនោះគឺការបង្កើតធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធពហុភាគីអាស៊ី (AIIB) ដែលដឹកនាំដោយប្រទេសចិន។ ប្រទេសចិនក៏បានបង្កើតមូលនិធិវិនិយោគជាច្រើនផងដែរនៅក្នុងឆ្នាំកន្លងទៅថ្មីៗនេះ ដូចជា មូលនិធិផ្លូវសូត្រ ហើយបានដាក់បញ្ចូលមូលធនបន្ថែមទៀតទៅក្នុងធនាគារគោលនយោបាយរបស់ខ្លួន ដែលផ្តោតជាពិសេសលើការគាំទ្រដល់ប្រតិបត្តិការក្រៅប្រទេស។ បន្ថែមពីនេះទៀត តាមរយៈការផ្តួចផ្តើមគំនិតខ្សែក្រវ៉ាត់មួយផ្លូវមួយ ដែលត្រូវបានប្រកាសផ្សព្វផ្សាយនៅឆ្នាំ២០១៣ រដ្ឋាភិបាលចិនបានផ្តល់ការគាំទ្រជាថ្មីឡើងវិញដល់ការវិនិយោគក្រៅប្រទេស។ ស្ថាប័ន និងការផ្តួចផ្តើមគំនិតថ្មីៗទាំងនេះ ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ បើគិតទៅលើសារៈសំខាន់ផ្នែកសេដ្ឋកិច្ច និងយុទ្ធសាស្ត្ររបស់តំបន់អាស៊ីអាគ្នេយ៍ចំពោះប្រទេសចិន ព្រមទាំងភូមិសាស្ត្រនៅក្បែរគ្នាផងនោះ តំបន់នេះត្រូវបានផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងផែនការរបស់ចិន សម្រាប់ការពង្រីកផ្គត់ផ្គង់ហិរញ្ញវត្ថុសម្រាប់ហេដ្ឋារចនាសម្ព័ន្ធក្រៅប្រទេស។

## ធនាគារវិនិយោគហេដ្ឋារចនាអាស៊ាន

ការបង្កើតឡើងនូវ AIIB បណ្តាលឱ្យមានភាពកក្រើករញ្ជួយដ៏ធំធេងបំផុតនៅក្នុងហិរញ្ញប្បទានអភិវឌ្ឍន៍ពហុភាគីសាកលលោក ដែលមិនធ្លាប់មានអស់រយៈពេលជាច្រើនទសវត្សរ៍មកហើយ។ គិតមកដល់ពាក់កណ្តាលឆ្នាំ២០១៦ មានប្រទេសចំនួន ៥៧ បានចុះហត្ថលេខាក្នុងនាមជាសមាជិកស្ថាបនិករបស់ធនាគារនេះ។ មូលធនទទួលបានការអនុញ្ញាតិដំបូងរបស់ AIIB គឺមានទឹកប្រាក់ ១០០ ពាន់លានដុល្លារអាមេរិក។ ប្រទេសចិនក្តាប់ភាគហ៊ុនច្រើនជាងគេបំផុត ដោយក្នុងនោះស្មើនឹងប្រមាណ ៣០% នៃភាគហ៊ុនសរុប និងគ្រប់គ្រងជាង ២៦% នៃភាគហ៊ុនបោះឆ្នោតរបស់ធនាគារ។ ធនាគារនឹងបន្តផ្តោតការយកចិត្តទុកដាក់លើការផ្តល់ហិរញ្ញប្បទានដល់ហេដ្ឋារចនាសម្ព័ន្ធ និង"វិស័យផលិតភាពដទៃទៀត" ក្នុងទ្វីបអាស៊ី ក្នុងគោលបំណងជម្រុញការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព ការបង្កើតធនធាន និងការកែលម្អការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធក្នុងទ្វីបអាស៊ី។[1] ធនាគារបានប្រកាសអំពីកញ្ចប់គម្រោងដំបូងរបស់ខ្លួននៅខែមេសា និងខែឧសភា ឆ្នាំ២០១៦ ដោយរួមមានទាំងគម្រោងផ្លូវហាយវេនៅប្រទេសប៉ាគីស្ថាន និងប្រទេសតាជីគីស្ថាន ការផ្គត់ផ្គង់ថាមពលក្នុងប្រទេសបង់ក្លាដេស និងការកែលម្អតំបន់អាណាធិបតេយ្យក្នុងប្រទេសឥណ្ឌូនេស៊ី។

ថ្នាក់គ្រប់គ្រងរបស់ AIIB ទំនងជាមានអំណាចធំធេងជាងក្នុងការអនុម័តលើគម្រោងនានា បើប្រៀបធៀបជាមួយថ្នាក់គ្រប់គ្រងនៅតាមស្ថាប័នហិរញ្ញវត្ថុអន្តរជាតិនានា ដូចជាធនាគារពិភពលោក ឬធនាគារអភិវឌ្ឍន៍អាស៊ី ដែលមានក្រុមប្រឹក្សាភិបាលជាអ្នកមើលការខុសត្រូវលើការសម្រេចចិត្តប្រភេទនេះ។[2] លោក Jin Liqun ដែលជាប្រធានធនាគារ AIIB បានសង្កត់ធ្ងន់លើការប្តេជ្ញាចិត្តរបស់ AIIB ក្នុងការរក្សាភាព "ស្អាតស្អំ" ហើយបានប្តេជ្ញាចិត្តបង្កើតវប្បធម៌ស្ថាប័នដ៏រឹងមាំដោយផ្អែកលើបទដ្ឋានសីលធម៌ ព្រមទាំងមិនអធ្យាស្រ័យដាច់ខាតចំពោះអំពើពុករលួយ។[3] ក្នុងឆ្នាំ២០១៥ ធនាគារ AIIB បានរៀបចំការពិគ្រោះយោបល់ខ្លីៗជាមួយស្ថាប័នសាធារណៈ និងស្ថាប័នឯកជន ស្តីពីការបង្កើតក្របខ័ណ្ឌការងារផ្នែកបរិស្ថាន និងសង្គមរបស់ខ្លួន ដែលជាដំណើរការរងការរិះគន់ពីក្រុមសង្គមស៊ីវិលថា នៅមិនទាន់មានភាពគ្រប់គ្រាន់នៅឡើយ។ ធនាគារបានអនុម័តលើក្របខ័ណ្ឌការងារនេះនៅឆ្នាំ២០១៦ ព្រមជាមួយគោលនយោបាយផ្តល់ព័ត៌មានជាសាធារណៈបណ្តោះអាសន្ន គោលនយោបាយលទ្ធកម្មរបស់សាជីវកម្ម និងក្រមសីលធម៌។

ក្របខ័ណ្ឌការងារផ្នែកបរិស្ថាន និងសង្គម កំណត់ឱ្យ AIIB ត្រូវប្តេជ្ញាចិត្តក្នុងការឈានទៅអនុវត្តគម្រោងប្រកបដោយនិរន្តរភាព ការពារក្រុមងាយរងគ្រោះ និងធានាឱ្យមានការចូលរួមពីភាគីពាក់ព័ន្ធ។ ទោះយ៉ាងណាក្តី ក្របខ័ណ្ឌការងារនេះនៅមានចំណុចខ្សោយ និងភាពខ្វះចន្លោះជាច្រើន ចំណែកបទដ្ឋានក្នុងការដោះស្រាយផលប៉ះពាល់ និងបទដ្ឋានស្តីពីជនជាតិដើមភាគតិច សុទ្ធតែមានកម្រិតទាបជាងបទដ្ឋាននៃការអនុវត្តល្អ និងបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ។

ប្រទេសចិនចង់សង្កត់ធ្ងន់ឱ្យឃើញថា AIIB នឹងជួយបំពេញបន្ថែមលើការងាររបស់ស្ថាប័នហិរញ្ញវត្ថុពហុភាគីដែលមានស្រាប់ ជាជាងដើរតួជាគូប្រជែងរបស់ស្ថាប័នទាំងនោះ។ នៅឆ្នាំ២០១៦ ធនាគារ AIIB បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងសហប្រតិបត្តិការជាមួយធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី ធនាគារវិនិយោគអឺរ៉ុប និងធនាគារអឺរ៉ុបសម្រាប់ការស្តារ និងអភិវឌ្ឍ។ ស្ថាប័នដទៃជាច្រើនទៀត បានបង្ហាញឆន្ទៈរបស់ខ្លួនដើម្បីធ្វើការជាមួយធនាគារនេះនាពេលអនាគត។ ជាពិសេសគឺ គម្រោងដែលធនាគារនេះផ្តល់ហិរញ្ញប្បទានរួមគ្នាជាមួយធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងស្ថាប័នប្រហាក់ប្រហែល ទំនងជានឹងយកបទដ្ឋាន ឬគោលនយោបាយការពារសង្គម និងបរិស្ថានរបស់ស្ថាប័នទាំងនោះមកអនុវត្ត។ ការផ្តល់ហិរញ្ញប្បទានរួមគ្នាជាមួយធនាគារពិភពលោក ឬធនាគារអភិវឌ្ឍន៍អាស៊ី ក៏ទំនងជាមានន័យថា ប្រសិនបើមានប្រជាពលរដ្ឋរងគ្រោះដោយសារគម្រោង ពួកគេអាចដាក់ពាក្យបណ្តឹងទៅកាន់យន្តការគណនេយ្យភាពរបស់ស្ថាប័នដែលមានស្រាប់ទាំងនេះបាន។

ចាប់តាំងពីការប្រកាសបង្កើត AIIB មក មានការពិភាក្សាជាច្រើនថា ធនាគារនេះនឹងក្លាយជាដៃគូប្រកួតប្រជែងរបស់ស្ថាប័នហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍដែលបានបង្កើតកន្លងមក។ ទោះយ៉ាងណាក្តី AIIB ត្រូវការពេលវេលាដើម្បីស្ថាបនាខ្លួនឯង និងសន្ទុះឈានឡើងរបស់ខ្លួន។ ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិដែលមានស្រាប់ បានបង្ហាញការស្វាគមន៍ជាសាធារណៈចំពោះ AIIB ហើយនឹងធ្វើជាសហអ្នកផ្តល់ហិរញ្ញប្បទានចំពោះគម្រោងដំបូងៗជាច្រើនរបស់ធនាគារនេះ។ សកម្មភាពនេះ ផ្តល់ឱកាសឱ្យ AIIB អាចរៀនសូត្រអំពីប្រព័ន្ធធានាសុវត្ថិភាព និងប្រព័ន្ធគណនេយ្យភាពរបស់ស្ថាប័នទាំងនោះ។ម្យ៉ាងទៀត នេះក៏ជាច្រកចូលប្រកបដោយសក្តានុពលសម្រាប់ក្រុមសង្គមស៊ីវិលក្នុងតំបន់អាស៊ី និងតំបន់ផ្សេងពីនេះ ដើម្បីចូលរួមជាមួយ AIIB តាមរយៈច្រក និងបណ្តាញការប្រាស្រ័យទាក់ទងដែលមានស្រាប់ជាមួយស្ថាប័នហិរញ្ញវត្ថុដទៃទៀត។

## ការផ្តួចផ្តើមគំនិតខ្សែក្រវ៉ាត់មួយផ្លូវមួយ

ការផ្តួចផ្តើមគំនិតខ្សែក្រវ៉ាត់មួយផ្លូវមួយដែលត្រូវបានប្រកាសនៅឆ្នាំ២០១៣ ក្នុងគោលបំណងបង្កើនការតភ្ជាប់រវាងប្រទេសចិន ជាមួយតំបន់អាស៊ី មជ្ឈឹមបូព៌ា អាហ្វ្រិក និងអឺរ៉ុប តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្នែកការដឹកជញ្ជូន ថាមពល ពាណិជ្ជកម្ម និងការប្រាស្រ័យទាក់ទង។ ការផ្តួចផ្តើមគំនិតខ្សែក្រវ៉ាត់មួយផ្លូវមួយ លើកកម្ពស់ការវិនិយោគ និងកិច្ចសហប្រតិបត្តិការក្នុងវិស័យជាច្រើន រួមទាំងវិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងថាមពល។[4] ការផ្តួចផ្តើមគំនិតខ្សែក្រវ៉ាត់មួយផ្លូវមួយកំណត់នូវចក្ខុវិស័យទូទៅមួយសម្រាប់ការវិនិយោគរបស់ចិននៅក្នុងឆ្នាំខាងមុខ ជាជាងគ្រាន់តែដើរតួនាទីជាផែនការជាក់ស្តែង ឬជាគ្រឹះស្ថានផ្តល់ហិរញ្ញវត្ថុទោលតែមួយ។ រដ្ឋាភិបាលចិនបានគូសបញ្ជាក់ថា មានបណ្តាប្រទេសជាង ៦០ ប្រទេសបានចូលរួមក្នុងការផ្តួចផ្តើមគំនិតនេះ។

ប្រទេសចិនបានសង្កត់ធ្ងន់អំពីផលប្រយោជន៍ទ្វេភាគីរបស់ការផ្តួចផ្តើមគំនិតខ្សែក្រវ៉ាត់មួយផ្លូវមួយ និងសក្តានុពលក្នុងការបង្កើតកិច្ចសហប្រតិបត្តិការ និងការវិនិយោគ ដើម្បីផ្តល់ប្រយោជន៍ដល់បណ្តាប្រទេសដែលមានហេដ្ឋារចនាសម្ព័ន្ធមិនសូវជឿនលឿន។ ការផ្តួចផ្តើមគំនិតនេះ ដើរតួជាផែនទីបង្ហាញផ្លូវក្នុងការសម្របសម្រួលសមាហរណកម្មចិនចូលទៅក្នុងសេដ្ឋកិច្ចពិភពលោកផង និងក្នុងការបង្កើនឥទ្ធិពលផ្នែកសេដ្ឋកិច្ចរបស់ប្រទេសនេះទៅក្នុងតំបន់ទាំងនោះផង។ ប្រទេសជាច្រើនតាមបណ្តោយផ្លូវនេះ មានចំណងទាក់ទងផ្នែកពាណិជ្ជកម្ម និងការវិនិយោគទុនយ៉ាងជិតស្និទ្ធជាមួយប្រទេសចិនរួចស្រេចទៅហើយ ដូច្នេះហើយការផ្តួចផ្តើមគំនិតនេះ ទំនងជាគាំទ្រដល់ការរឹតចំណងទំនាក់ទំនងនេះឱ្យកាន់តែមានភាពស៊ីជម្រៅថែមទៀត។ ចក្ខុវិស័យរបស់ការផ្តួចផ្តើមគំនិតខ្សែក្រវ៉ាត់មួយផ្លូវមួយ សង្កត់ធ្ងន់លើសារៈសំខាន់នៃភាគនីរតីប្រទេសចិនជាច្រកសម្រាប់ផ្លូវសូត្រដីគោកផង និងផ្លូវសូត្រសមុទ្រផង ដោយក្នុងនោះរួមទាំងផ្លូវដែលឆ្លងកាត់ប្រទេសភូមាឡាវ និងវៀតណាម ដែលជាផ្នែកមួយរបស់ "តំណរភ្ជាប់នៃការបើកទ្វារប្រទេសចិនទៅកាន់អាស៊ីខាងត្បូង និងអាស៊ីអាគ្នេយ៍"។[5]

គម្រោងនានាដែលស្ថិតនៅក្នុងការផ្តួចផ្តើមគំនិតខ្សែក្រវ៉ាត់មួយផ្លូវមួយ នឹងត្រូវការទឹកប្រាក់រាប់ពាន់លានដុល្លារ ក្នុងរយៈពេលប៉ុន្មានឆ្នាំខាងមុខនេះ។ ការផ្គត់ផ្គង់ហិរញ្ញវត្ថុ នឹងបានមកពីប្រភពហិរញ្ញវត្ថុជាច្រើន ដោយភាគច្រើនគឺពុំមែនជាប្រភពហិរញ្ញវត្ថុថ្មីនោះឡើយ។ ឧទាហរណ៍ ធនាគារគោលនយោបាយចិន រួមទាំងធនាគារអភិវឌ្ឍន៍ចិនជាដើម បានផ្តល់ហិរញ្ញប្បទានដល់គម្រោងនានា ដែលបច្ចុប្បន្នបានក្លាយជាច្រកផ្លូវខ្សែក្រវ៉ាត់មួយផ្លូវមួយ អស់ពេលជាងមួយទសវត្សរ៍មកហើយ។ ធនាគារពាណិជ្ជកម្មចិនជាច្រើន ក៏កំពុងធ្វើការងារយ៉ាងសកម្ម នៅក្នុងបណ្តាប្រទេសជាច្រើនតាមបណ្តោយផ្លូវនេះ មិនខុសអ្វីពីមូលនិធិភាគហ៊ុន និងក្រុមហ៊ុនវិនិយោគទុនចិននោះដែរ។ អង្គភាពជាច្រើនក្នុងចំណោមអង្គភាពទាំងនេះ បានបង្កើតមូលនិធិថ្មីៗ និងបានទទួលមូលនិធិបន្ថែមពីរដ្ឋ ជាពិសេសសម្រាប់គាំទ្រគម្រោងនានានៅក្នុងការផ្តួចផ្តើមគំនិតខ្សែក្រវ៉ាត់មួយផ្លូវមួយ។ ធនាគារ AIIB ក៏ទំនងជាផ្តល់ហិរញ្ញវត្ថុដល់គម្រោងនានានៅតាមបណ្តោយផ្លូវរបស់ការផ្តួចផ្តើមគំនិតនេះផងដែរ។

## មូលនិធិវិនិយោគគាំទ្រដោយរដ្ឋ

ប្រភពហិរញ្ញវត្ថុដ៏សំខាន់មួយទៀតសម្រាប់ការវិនិយោគក្រៅប្រទេសរបស់ចិន គឺមូលនិធិវិនិយោគគាំទ្រដោយរដ្ឋ។ មូលនិធិវិនិយោគប្រភេទនេះចំនួនពីរ កំពុងមានប្រតិបត្តិការនៅក្នុងតំបន់របស់សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (អាស៊ាន) ពោលគឺមូលនិធិផ្លូវសូត្រ និងមូលនិធិវិនិយោគហេដ្ឋារចនាសម្ព័ន្ធចិន-អាស៊ាន ដោយមូលនិធិទាំងពីរនេះមានផែនការពង្រីកប្រតិបត្តិការនៅក្នុងឆ្នាំខាងមុខនេះ។

មូលនិធិផ្លូវសូត្រដែលមានទឹកប្រាក់ ៤០ ពាន់លានដុល្លារអាមេរិកត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៤ ដោយមានគោលបំណងលើកកម្ពស់ "ការអភិវឌ្ឍ និងវិបុលភាពរួមរបស់ប្រទេសចិន និងបណ្តាប្រទេស ព្រមទាំងតំបន់នានាដែលពាក់ព័ន្ធក្នុងការផ្តួចផ្តើមគំនិតខ្សែក្រវ៉ាត់មួយផ្លូវមួយ"។[6] មូលនិធិនេះ សង្កត់ធ្ងន់លើការវិនិយោគលើគម្រោង និងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធធំៗ។ មូលនិធិផ្លូវសូត្រគូសបញ្ជាក់ថា មូលនិធិពុះពារលើកកម្ពស់ការអភិវឌ្ឍមានភាពអំណោយផលដល់បរិស្ថាន និងមាននិរន្តរភាព និង "គោរពតាមបទដ្ឋាន និងនិយាមអន្តរជាតិ ហើយគោរពតាមច្បាប់ និងបទបញ្ញានានារបស់ប្រទេសចិន និងប្រទេសម្ចាស់ផ្ទះ។"[7] ទោះយ៉ាងណាក្តី នៅមានភាពមិនច្បាស់លាស់ ថាតើមានប្រព័ន្ធសម្រាប់ការវាយតម្លៃ និងកាត់បន្ថយផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថានណាមួយហើយឬនៅ នៅក្នុងគម្រោងនានាដែលមូលនិធិនេះវិនិយោគជាមួយ។

មូលនិធិសហប្រតិបត្តិការវិនិយោគចិន-អាស៊ាន (CAF) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៣ ហើយផ្តោតគោលដៅចំពោះការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធ ថាមពល និងធនធានធម្មជាតិក្នុងបណ្តាប្រទេសអាស៊ាន។[8] មូលនិធិនេះត្រូវបានបង្កើតឡើងដោយមានទុនដំបូងចំនួន ១ ពាន់លានដុល្លារអាមេរិក ប៉ុន្តែមានគោលដៅបង្កើនទុនទៅដល់ ១០ ពាន់លានដុល្លារអាមេរិក។ ធនាគារនាំចេញ-នាំចូលរបស់ចិន (Eximbank) បានដឹកនាំការបង្កើតមូលនិធិនេះ ហើយគឺជាអ្នកឧបត្ថម្ភចម្បង ដោយបានចូលរួមវិភាគទានទឹកប្រាក់ចំនួន ៣០០ លានដុល្លារអាមេរិកទៅក្នុងដើមទុនដំបូងរបស់មូលនិធិនេះ។ សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិរបស់ធនាគារពិភពលោក មានភាគហ៊ុននៅក្នុង CAF ហើយបានចូលរួមវិភាគទានទឹកប្រាក់ចំនួន ១០០ លានដុល្លារអាមេរិក ស្មើនឹង ១០% នៃថវិកាជំហានទីមួយរបស់មូលនិធិនេះ។[9] នៅក្នុងជំហានទីមួយនេះ CAF បានវិនិយោគក្នុងគម្រោងចំនួន ១១ ដោយក្នុងនោះរួមមានទាំងគម្រោងផ្នែកទូរគមនាគមន៍ អាជីវកម្មរ៉ែ ដឹកជញ្ជូន និងថាមពល។ ប្រទេសចិនមានបំណងបង្កើនទឹកប្រាក់ ៣ ពាន់លានដុល្លារសម្រាប់ជំហានទីពីររបស់មូលនិធិ។[10]

គេហទំព័ររបស់ CAF បញ្ជាក់ថាមូលនិធិ "មានជំនាញផ្នែកការវិនិយោគប្រកបដោយនិរន្តរភាព ដែលមិនត្រឹមតែនាំយកភាពរីកចម្រើនផ្នែកហិរញ្ញវត្ថុឱ្យដល់ក្រុមហ៊ុនទទួលការវិនិយោគតែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងនាំមកនូវគុណតម្លៃគួរជាទីកត់សម្គាល់សម្រាប់សហគមន៍ផងដែរ។"[11] ក្នុងខែកក្កដា ឆ្នាំ២០១៤ CAF បានចេញផ្សាយគោលការណ៍ណែនាំស្តីពីការទទួលខុសត្រូវផ្នែកសង្គម និងកិច្ចការពារបរិស្ថានសម្រាប់ការវិនិយោគក្នុងតំបន់អាស៊ាន ដែលមានខ្លឹមសារកែសម្រួលចេញពីបទដ្ឋានការអនុវត្តការងាររបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ។ ក្រុមហ៊ុន និងគម្រោងទាំងអស់ដែលទទួលការវិនិយោគពី CAF ចាំបាច់ត្រូវតែអនុវត្តតាមគោលការណ៍ណែនាំនេះ។ ការអនុម័ត និងបោះពុម្ពផ្សាយគោលការណ៍ណែនាំរបស់ CAF តំណាងឱ្យការឈានមួយជំហានទៅមុខ លើផ្នែកអភិបាលកិច្ចសង្គម និងបរិស្ថាន ដែលពុំទាន់មានមូលនិធិដឹកនាំដោយប្រទេសចិន

ណាមួយផ្សេងទៀតធ្លាប់បានធ្វើនៅឡើយទេរហូតមកទល់ពេលនេះ។ ថ្វីបើមូលនិធិនៅមិនទាន់បានបង្កើតយន្តការបណ្តឹងក្តី ប៉ុន្តែភាគហ៊ុន ១០% របស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិនៅក្នុងមូលនិធិនេះ មានន័យថា គេអាចដាក់ពាក្យបណ្តឹងទៅកាន់ការិយាល័យភាពអនុលោម ទីប្រឹក្សា ដោះស្រាយវិវាទ ដែលជាយន្តការគណនេយ្យភាពរបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិបាន។

## ធនាគារគោលនយោបាយរបស់ចិន

របាយការណ៍របស់យើង ពិនិត្យភាគច្រើនទៅលើការវិវឌ្ឍន៍នាពេលថ្មីៗ និងការវិវឌ្ឍន៍ជាបន្តបន្ទាប់នៅក្នុងការផ្តល់ហិរញ្ញវត្ថុលើហេដ្ឋារចនាសម្ព័ន្ធក្រៅប្រទេសរបស់ចិន។ ប៉ុន្តែ ធនាគារគោលនយោបាយរបស់ចិន មានប្រតិបត្តិការនៅក្រៅប្រទេសអស់រយៈពេលជាងមួយទសវត្សរ៍មកហើយ ក្នុងការគាំទ្រយុទ្ធសាស្រ្តចេញទៅក្រៅប្រទេសរបស់ប្រទេសនេះ។ តាមរយៈយុទ្ធសាស្រ្តនេះ រដ្ឋចិនបានលើកកម្ពស់ក្រុមហ៊ុនចិនឱ្យពង្រីកនៅក្រៅប្រទេស ដោយប្រើប្រាស់រូបិយវត្ថុបរទេសដែលលើសតម្រូវការប្រទេស ដើម្បីបង្កើនលទ្ធភាពចូលទៅកាន់ទីផ្សារ ធនធានធម្មជាតិ និងបច្ចេកវិទ្យាសាកល។ ធនាគារអភិវឌ្ឍន៍ចិន និងធនាគារ Eximbank បានដើរតួយ៉ាងសំខាន់ក្នុងការជម្រុញយុទ្ធសាស្រ្តនេះ ដោយបានវិនិយោគទឹកប្រាក់រាប់ពាន់លានដុល្លារអាមេរិកនៅក្រៅប្រទេស។ ចាប់តាំងពីបានប្រកាសការផ្តួចផ្តើមគំនិតខ្សែក្រវ៉ាត់មួយផ្លូវមួយមក រដ្ឋាភិបាលចិនបានដាក់មូលធនបន្ថែមក្នុងចំនួនទឹកប្រាក់គួរជាទីកត់សម្គាល់ចូលទៅក្នុងធនាគារទាំងពីរនេះ។

ទាំងធនាគារអភិវឌ្ឍន៍ចិន និងធនាគារ Eximbank ចិន គឺសុទ្ធតែមានបទដ្ឋានបរិស្ថាន និងសង្គម។ ធនាគារអភិវឌ្ឍន៍ចិនមិនដែលបានបោះពុម្ពផ្សាយគោលនយោបាយរបស់ខ្លួនទេ ប៉ុន្តែធនាគារ Eximbank ចិន បានចេញផ្សាយគោលនយោបាយមូលដ្ឋានស្តីពីការវាយតម្លៃផ្នែកបរិស្ថានរបស់ខ្លួន សម្រាប់គម្រោងក្នុងប្រទេស និងក្រៅប្រទេស។ ធនាគារទាំងពីរនេះ មានអំណាចចេញការព្រមានដល់អតិថិជនដែលពុំគ្រប់គ្រងហានិភ័យផ្នែកបរិស្ថាន និងសង្គមនៅក្នុងគម្រោងរបស់ខ្លួនឱ្យបានសមស្រប។ ទោះយ៉ាងណាក្តី ពុំមានធនាគារណាមួយក្នុងចំណោមធនាគារទាំងពីរបានបោះពុម្ពផ្សាយនូវព័ត៌មានលម្អិតអំពីគម្រោង ហើយការវាយតម្លៃពុំត្រូវបានធ្វើឡើងក្នុងលក្ខណៈបើកចំហ និងប្រកបដោយតម្លាភាពឡើយ។ ម្យ៉ាងទៀត ពុំមានច្រកផ្លូវការណាមួយ ដែលប្រជាជនរងផលប៉ះពាល់អាចដាក់ពាក្យបណ្តឹងរបស់ខ្លួនបានឡើយ។ កង្វះតម្លាភាពបែបនេះបានកម្រិតប្រសិទ្ធភាពគោលនយោបាយផ្នែកសង្គម និងបរិស្ថានរបស់ធនាគារទាំងពីរនេះយ៉ាងខ្លាំង។

## សន្និដ្ឋាន

ប្រទេសចិនបានដើរតួនាទីយ៉ាងធំធេងរួចមកហើយនៅក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ថាមពល និងទូរគមនាគមន៍ក្នុងតំបន់អាស៊ីអាគ្នេយ៍។ ចិនគឺជាអ្នកវិនិយោគកំពូលមួយនៅក្នុងប្រទេសកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា ចំណែកការវិនិយោគរបស់ចិននៅប្រទេសវៀតណាម ថៃ ម៉ាឡេស៊ី និងឥណ្ឌូនេស៊ីក៏មានកម្រិតគួរជាទីកត់សម្គាល់ និងកំពុងមានការកើនឡើងផងដែរ។ បណ្តាប្រទេសអាស៊ានទាំងដប់បានចុះហត្ថលេខាជាសមាជិករបស់ AIIB ហើយតំបន់នេះក៏ស្ថិតនៅក្នុងវង្វង់ការផ្តួចផ្តើមគំនិតខ្សែក្រវ៉ាត់មួយផ្លូវមួយផងដែរ។ លទ្ធភាពទទួលបានការផ្តត់ផ្គង់ហិរញ្ញវត្ថុកាន់តែច្រើនលើផ្នែកហេដ្ឋារចនាសម្ព័ន្ធនេះ ទំនងជានឹងមានផលប៉ះពាល់គួរឱ្យសម្គាល់នៅក្នុងតំបន់អាស៊ានទាំងមូល។

តំបន់អាស៊ីជួបប្រទះការខ្វះខាតមូលនិធិគួរឱ្យសម្គាល់សម្រាប់ផ្នែកហេដ្ឋារចនាសម្ព័ន្ធ ហើយរដ្ឋាភិបាលនៃបណ្តាប្រទេសអាស៊ានដ៏ច្រើនលើសលប់ បង្ហាញយ៉ាងច្បាស់នូវបំណងចង់ទាក់ទាញការវិនិយោគទុនលើគម្រោងខ្នាតធំ។ ស្ថាប័ន និងការផ្តួចផ្តើមគំនិតដែលយើងបានពិភាក្សាក្នុងឯកសារនេះ អាចចូលរួមវិភាគទានក្នុងការឆ្លើយតបចំពោះសេចក្តីត្រូវការនេះ ហើយអាចមានសក្តានុពលជម្រុញឱ្យមានលំហូរមូលធនខ្នាតធំចូលមកក្នុងតំបន់ ដែលនឹងគាំទ្រដល់ការចាប់ផ្តើមអនុវត្តផែនការវិនិយោគទុនផ្នែកហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់កាន់តែឆាប់រហ័សថែមទៀត និងចូលរួមវិភាគទានក្នុងការពង្រឹងការតភ្ជាប់រវាងប្រទេសចិន និងអាស៊ាន ក៏ដូចជារវាងបណ្តាប្រទេសជាសមាជិកអាស៊ានផ្ទាល់ផងដែរ។ ស្របពេលជាមួយគ្នានេះផងដែរ បើគ្មានតម្លាភាព ការធានាសុវត្ថិភាព និងគណនេយ្យភាពឱ្យបានគ្រប់គ្រាន់ទេនោះ អត្ថប្រយោជន៍នានាអាចនឹងត្រូវរលាយបាត់បង់ ដោយសារតែផលប៉ះពាល់អវិជ្ជមានដែលកើតមានចំពោះមនុស្ស និងបរិស្ថាន។

មូលនិធិសហប្រតិបត្តិការវិនិយោគចិន-អាស៊ាន (CAF) បានអនុម័តគោលនយោបាយដោយផ្អែកលើបទដ្ឋានការអនុវត្តការងាររបស់សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ហើយ AIIB បានអនុម័តលើក្របខ័ណ្ឌការងារផ្នែកបរិស្ថាន និងសង្គមមួយ ដោយក្នុងនោះយន្តការបណ្តឹងសារទុក្ខកំពុងត្រូវបានអភិវឌ្ឍឡើង។ ទោះយ៉ាងណាក្តី ការធានាសុវត្ថិភាពផ្នែកសង្គម និងបរិស្ថានរបស់អ្នកផ្តល់ហិរញ្ញវត្ថុចិន ជាទូទៅគឺមានលក្ខណៈជាមូលដ្ឋានប៉ុណ្ណោះ និងរមែងតែងមិនបើកចំហរឱ្យមានការផ្តល់មតិ និងការត្រួតពិនិត្យពីសាធារណៈជនឡើយ។ ពុំមានអ្នកផ្តល់ហិរញ្ញវត្ថុទ្វេភាគីណាមួយ ដែលយើងបានពិភាក្សាកន្លងមកក្នុងឯកសារនេះ មានឯកសារទូលំទូលាយអំពីគម្រោង ហើយក៏ពុំទាន់មានស្ថាប័នមួយមានយន្តការបណ្តឹងសារទុក្ខ ឬយន្តការគណនេយ្យភាពដែរ។ យោងតាមបរិបទនេះ និងអាស្រ័យដោយយន្តការការពារសុវត្ថិភាពរបស់ AIIB នៅពុំទាន់បានអនុវត្តសាកល្បងនៅឡើយ រាល់ការបន្ថែមកម្ចីផ្នែកហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់ ចាំបាច់ទាមទារឱ្យមានការពិនិត្យតាមដានយ៉ាងម៉ត់ចត់។

ក្រុមសង្គមស៊ីវិលនៅក្នុងតំបន់ អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការពិនិត្យតាមដាន និងចូលរួមជាមួយការផ្តួចផ្តើមគំនិតទាំងអស់នេះ។ តាមរយៈការអភិវឌ្ឍការយល់ដឹងកាន់តែស៊ីជម្រៅថែមទៀតអំពីស្ថាប័ន និងការផ្តួចផ្តើមគំនិតទាំងនេះ ពិនិត្យតាមដានលើការអភិវឌ្ឍ និងសកម្មភាពរបស់ពួកគេ និងលើកកម្ពស់ការយល់ដឹងសាធារណៈ សង្គមស៊ីវិលនឹងស្ថិតក្នុងឋានៈល្អប្រសើរជាងមុនក្នុងការជម្រុញឱ្យមានបទដ្ឋានរឹងមាំ និងគណនេយ្យភាពកាន់តែខ្ពស់ថែមទៀត ដើម្បីការពារសហគមន៍រងផលប៉ះពាល់ និងប្រព័ន្ធអេកូឡូស៊ី។

*ព្រឹត្តិប័ត្រព័ត៌មាននេះដកស្រង់ចេញពីរបាយការណ៍អង្គការ Inclusive Development International ដែលមានចំណងជើងថា [Making Inroads: Chinese Infrastructure Investment in ASEAN and Beyond]* ។ *ការស្រាវជ្រាវ និង ការអភិវឌ្ឍឯកសារបោះពុម្ពផ្សាយនេះ បានទទួលការគាំទ្រពី Heinrich-Böll-Stiftung South East Asia,The McKnight Foundation and Planet Wheeler Foundation*

*ការបោះពុម្ពផ្សាយនេះបានទទួលអាជ្ញាប័ណ្ណអនុញ្ញាតក្រោម Creative Commons Attribution-NonCommercial-ShareAlike 4.0 International License*

---

[1] AIIB (2015), *Articles of Agreement*, article 1.

[2] Donnan, S. &Sevastopulo, D. (2015, 25 October), *AIIB head vows to be clean, lean and green — and fast*, Financial Times.http://www.ft.com/cms/s/0/b6f95846-7b0d-11e5-a1fe-567b37f80b64.html (accessed May 2016).

[3] AIIB (2015, 26 August), *Statement by JinLiqun at a Press Conference in Tbilisi*.http://www.aiib.org/html/2015/NEWS_0826/16.html (accessed May 2016).

[4] National Development and Reform Commission, Ministry of Foreign Affairs & Ministry of Commerce of the People's Republic of China (2015), *Vision and Actions on Jointly Building Silk Road Economic Belt and 21st-Century Maritime Silk Road*. http://en.ndrc.gov.cn/newsrelease/201503/t20150330_669367.html (accessed May 2016).

[5] *Ibid*.

[6] Silk Road Fund (2015), *About Us*.http://www.silkroadfund.com.cn/enweb/23775/23767/index.html (accessed May 2016).

[7] Silk Road Fund (2015), *Scope ofInvestment Principles*. http://www.silkroadfund.com.cn/enweb/23798/23805/index.html (accessed May 2016).

[8] China-ASEAN Investment Cooperation Fund, *About CAF: Mission & Vision*. http://www.china-asean-fund.com/about-caf.php?slider1=1 (accessed May 2016).

[9] International Finance Corporation (2010, 25 January), *China-ASEAN Fund on Investment Cooperation: Summary of Proposed Investment*. http://ifcext.ifc.org/ifcext/spiwebsite1.nsf/0/EA30D66D3BCEE0F9852576BA000E3309 (accessed May 2016).

[10] Li, K. (2015, 13 November), *Remarks by H.E. Li Keqiang Premier of the State Council of the People's Republic of China At the 17th ASEAN-China Summit*, Ministry of Foreign Affairs of the People's Republic of China. http://www.fmprc.gov.cn/mfa_eng/zxxx_662805/t1212266.shtml (accessed November 2015).

[11] China-ASEAN Investment Cooperation Fund, *About CAF: Background*. http://www.china-asean-fund.com/about-caf.php?slider1=2 (accessed November 2015).